ភ្នំពេញ , ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៣

# សារាចរ លេខ ០២ សរ

* * *

សហប្រធានរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា

## សូមជំរាបមក

អស់លោក អភិបាល ខេត្ត ក្រុងទូទាំងប្រទេស

**កម្មវត្ថុ :** អំពីរបៀបរៀបរយ និង សន្តិសុខសាធារណៈ ។

មតិសាធារណៈ បានគត់សំគាល់ឃើញថា នៅខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ជាច្រើន ខ្វះ របៀបរៀបរយ និង សន្តិសុខសាធារណៈ ។ អំពើចោរកម្ម ឆក់ប្លន់ កាប់សម្លាប់ ប្រើប្រាស់គ្រឿងអាវុធ និង ជាតិផ្ទុះ ដោយឥត មានច្បាប់អនុញ្ញាតធ្វើអោយប្រជារាស្ត្រគ្មានការកក់ក្តៅ ចំពោះការរស់នៅសុខសាន្តរបស់គេដែលគេទាមទារយ៉ាងទទូច ។

រដ្ឋាភិបាល សូមអោយអភិបាល ខេត្ត ក្រុង ទូទាំងប្រទេសចាត់វិធានការជាបន្ទាន់ ដើម្បី បង្ក្រាបអំពើលួចប្លន់ កាប់សម្លាប់ និង ឆែកឆេរអាវុធ និង គ្រឿងផ្ទុះ ដែលកាន់កាប់ឥតមានច្បាប់អនុញ្ញាត ហើយបញ្ជូនជនប្រព្រឹត្តល្មើសទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ក្រោយបានទទួលសារាចរនេះ អភិបាល ខេត្ត ក្រុង ទាំងអស់ ត្រូវរាយការណ៍ជាលាយលក្ខណ៍ អក្សរមកក្រសួងមហាផ្ទៃ ក្នុងរយៈពេលមួយខែ នៅដំណាច់ ខែ កក្កដា ឆ្នាំ ១៩៩៣ អំពីលទ្ធផលដែល សំរេចបានក្នុងបញ្ហាទាំងអស់ខាងលើនេះ ។

**សហប្រធាន**

**រដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា**

ព្រះហស្តលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**